# ពលរដ្ឋឌីជីថល និងការត្រៀមខ្លួនរបស់កម្ពុជា

នាពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាដើរតួនាទីយ៉ាងសំខាន់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ទាំងការសិក្សា ការធ្វើអាជីវកម្ម និងការបំពេញកិច្ចការងារ។ មនុស្សគ្រប់វ័យ បាននិងកំពុងពឹងផ្អែកខ្លាំងលើឧបករណ៍ឌីជីថលសម្រាប់ការផ្សារភ្ជាប់ទំនាក់ទំនង ការស្រាវជ្រាវ ការវាយតម្លៃ និងការទទួលបានព័ត៌មាន ជាដើម។ ក្នុងន័យនេះ ការចាប់យកបច្ចេកវិទ្យាឌីជីថល មកប្រើប្រាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ទាមទារឱ្យប្រជាពលរដ្ឋគ្រប់រូបត្រូវមានចំណេះដឹង និងជំនាញទន់ចាំបាច់ ដើម្បីក្លាយខ្លួនជាពលរដ្ឋឌីជីថល និងជំរុញឱ្យការធ្វើអន្តរកម្មនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និងសង្គមឌីជីថល កាន់តែមានស័ក្តិសិទ្ធិភាព ដើម្បីធានានូវបរិយាបន្នឌីជីថល។ ដូច្នេះ ពលរដ្ឋឌីជីថល សំដៅដល់បុគ្គលទាំងឡាយណាដែលអាចប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ឌីជីថលសម្រាប់ការរស់នៅប្រចាំថ្ងៃ និងសម្រាប់ការអភិវឌ្ឍជំនាញ និងចំណេះដឹង។ ការក្លាយខ្លួនជាពលរដ្ឋឌីជីថលអាចធ្វើបានតាមរយៈការពង្រឹងសមត្ថភាពអក្ខរកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ ដែលអាចឱ្យខ្លួនចូលរួមលើកកម្ពស់នវានុវត្តន៍សង្គម សេដ្ឋកិច្ច នយោបាយ និងរដ្ឋាភិបាលឱ្យកាន់តែប្រសើរឡើង។

## I. ជំនាញសំខាន់ៗដែលអាចប្រែក្លាយពលរដ្ឋទៅជាពលរដ្ឋឌីជីថល

នាយុគសម័យឌីជីថល មនុស្សតែងតែប្រើប្រាស់នូវជំនាញឌីជីថលផ្សេងៗទៅតាមតម្រូវការរៀងៗខ្លួន ដើម្បីបំពេញកិច្ចការងារ និងសម្រួលដល់ជីវិតរស់នៅប្រចាំថ្ងៃ ។ ពលរដ្ឋឌីជីថលមិនត្រឹមតែមានន័យថាមានសម្ថភាពប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថលប៉ុណ្ណោះទេតែត្រូវមានជំនាញដែលអាចប្រើប្រាស់ប្រកបដោយទំនួលខុសត្រូវ សុវត្ថិភាព និងមានក្រមសីលធម៌ផងដែរ នោះទើបអាចក្លាយជាពលរដ្ឋឌីជីថលល្អ។ ក្នុងន័យនេះ ជំនាញខាងក្រោមនេះ ត្រូវបានរាប់បញ្ចូលជាចំណេះដឹងបច្ចេកវិទ្យា និងជំនាញទន់សំខាន់ៗ ដែលត្រូវមាន ដើម្បីអាចអោយពលរដ្ឋក្លាយជាពលរដ្ឋឌីជីថលបាន រួមមាន៖

### ▶ អក្ខរកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាដោយមានក្រមសីលធម៌

អក្ខរកម្មឌីជីថល សំដៅដល់សមត្ថភាពក្នុងការស្វែងរក វាយតម្លៃ ប្រើប្រាស់ បង្កើត និងចែករំលែកព័ត៌មានដោយសុវត្ថិភាព និងប្រសិទ្ធភាព តាមរយៈឧបករណ៍បច្ចេកវិទ្យា ដូចជា កុំព្យូទ័រ ទូរសព្ទដៃ និងអ៊ីនធឺណិតជាដើម។ ចំណេះដឹងនេះ រួមបញ្ចូលទាំងការយល់ដឹងពីបច្ចេកវិទ្យា, សុវត្ថិភាពបណ្តាញ, និងការប្រើប្រាស់ឧបករណ៍ឌីជីថលដោយការទទួលខុសត្រូវផងដែរ។ អក្ខរកម្មឌីជីថលនឹងចូលរួមយ៉ាងសំខាន់ដល់ការលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ សំដៅធានាបាននូវសេដ្ឋកិច្ច សង្គមមួយ

ប្រកបដោយសមធម៌ បរិយាបន្ន និងរីកចម្រើន។ ក្រៅពីនេះ មនុស្សត្រូវចេះប្រើប្រាស់ប្រកបដោយក្រមសីលធម៌ ដោយសង្កត់ធ្ងន់លើការយល់ចិត្ត និងការគោរពចំពោះគ្នា ដើម្បីការពារការគំរាមកំហែងតាមអ៊ីនធឺណិត និងស្វែងយល់ពីផលប៉ះពាល់ផ្នែកផ្លូវចិត្តដែលបណ្តាលមកពីការធ្វើអន្តរកម្មលើអ៊ីនធឺណិតហួសព្រំដែន ដែលទាំងនេះអាចធានាបាននូវបរិយាកាសឌីជីថលដែលមានសុវត្ថិភាព។

### ▶ ការយល់ដឹងអំពីសុវត្ថិភាពតាមអ៊ីនធឺណិត

សុវត្ថិភាពលើអ៊ីនធឺណិតសំដៅលើសមត្ថភាពក្នុងការការពារព័ត៌មានឯកជន និងរក្សាសុវត្ថិភាពក្នុងបរិយាកាសអនឡាញ។ នេះរួមបញ្ចូលទាំងការយល់ដឹងពីរបៀបការពារព័ត៌មានលម្អិតសំខាន់ៗ ដូចជា ឈ្មោះ ថ្ងៃកំណើត លេខសន្តិសុខសង្គម ឬអាសយដ្ឋានផ្ទះ ក៏ដូចជាការកំណត់មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណ (Authentication) ជាដើម។មនុស្សត្រូវដឹងពីព័ត៌មានណាដែលមានសុវត្ថិភាពក្នុងការចែករំលែក ជាពិសេសចំណេះដឹងអំពីសុវត្ថិភាពតាមអ៊ីនធឺណិតដើម្បីកាត់បន្ថយការគំរាមកំហែងតាមអ៊ីនធឺណិត ដូចជា ការបោកបញ្ឆោត ការបន្លំអត្តសញ្ញាណ និងការលួចចូលគណនីជាដើម។ ក្រៅពីជំនាញនេះ ដើម្បីក្លាយជាពលរដ្ឋឌីជីថលប្រកបដោយសមត្ថភាព មនុស្សក៏អាចចាប់យកជំនាញឌីជីថលកម្រិតខ្ពស់បន្ថែម ដូចជា ជំនាញសរសេរកូដ, ជំនាញបង្កើតកម្មវិធី និងជំនាញ AI ជាដើម ដើម្បីបង្កើនចំណេះដឹងបន្ថែមទាក់ទងនឹងជំនាញឌីជីថល ជាពិសេសជំរុញភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារការងារផងដែរ។

### ▶ ការវាយតម្លៃព័ត៌មាន

មនុស្សក៏ត្រូវមានសមត្ថភាពត្រិះរិះពិចារណា វិភាគទិន្នន័យ ឬព័ត៌មានមិនពិត ការឃោសនាបំភាន់ដោយចេតនា និងការក្លែងបន្លំជាដើម (រូបភាព វីដេអូ និងសំឡេងដែលបង្កើតឡើងដោយ AI) ដើម្បីអោយពួកគេចេះសំយោគព័ត៌មាន និងចេះប្រើប្រាស់ព័ត៌មានពីប្រភពដែលត្រឹមត្រូវ និងទុកចិត្តបាន។

### ▶ ការគ្រប់គ្រងខ្លួនឯង និងការគ្រប់គ្រងពេលវេលា

ពលរដ្ឋឌីជីថលដែលមានការទទួលខុសត្រូវ ត្រូវចេះរក្សាតុល្យភាពរវាងការប្រើប្រាស់បច្ចេកវិទ្យា និងសុខភាពផ្លូវកាយផ្លូវចិត្ត។ ដើម្បីចៀសវាងផលប៉ះពាល់ពីការប្រើប្រាស់អ៊ីនធឺណិតហួសកម្រិត ឬគ្រោះថ្នាក់ផ្សេងៗ យើងត្រូវមានម្ចាស់ការលើខ្លួនឯង និងគ្រប់គ្រងពេលវេលាក្នុងការប្រើប្រាស់វាឱ្យចំគោលដៅ។ ការចេះគ្រប់គ្រងខ្លួនឯងនិងពេលវេលា នឹងជួយឱ្យយើងប្រើប្រាស់បច្ចេកវិទ្យាក្នុងផ្លូវវិជ្ជមាន និងមានសុវត្ថិភាព។

## II. អត្ថប្រយោជន៍នៃពលរដ្ឋឌីជីថល

ការធានាបាននូវសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព និងបរិយាបន្ន ជាពិសេសនៅក្នុងបរិបទបច្ចុប្បន្ននៅពេលដែលបច្ចេកវិទ្យាជះឥទ្ធិពលស្ទើរតែគ្រប់សកម្មភាពប្រចាំថ្ងៃ ត្រូវការចាំបាច់ឱ្យប្រជាពលរដ្ឋមានចំណេះដឹង និងជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធឌីជីថល

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។ ក្នុងន័យនេះ ពលរដ្ឋឌីជីថល គឺជាគោលគំនិតដ៏សំខាន់ និងផ្តល់ឱ្យនូវអត្ថប្រយោជន៍ជាច្រើន ដែលនេះទាមទារឱ្យមានការគិតគូរ និងយកចិត្តទុកដាក់ក្នុងការជំរុញកិច្ចការងារនេះ។ ដូច្នេះ ខាងក្រោមនេះ នឹងបង្ហាញពីអត្ថប្រយោជន៍សំខាន់ៗនៃពលរដ្ឋឌីជីថល៖

### ➤ ជំរុញការសម្របបានទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និងការងារ

នាយុគសម័យឌីជីថល បច្ចេកវិទ្យាឌីជីថលបានបង្កើតជាប្រភេទការងារថ្មីៗជាច្រើន ដែលទាមទារឱ្យមានចំណេះដឹង និងជំនាញខ្ពស់ជាងមុន ជាពិសេសជំនាញឌីជីថល។ ក្នុងន័យនេះ កាលដែលពលរដ្ឋមានជំនាញឌីជីថល អាចធ្វើឱ្យពួកគេសម្របខ្លួនបានទាន់ពេលទៅនឹងការផ្លាស់ប្តូរនៃបរិបទការងារ, អាចរក្សាភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារការងារ និងជាពិសេសចូលរួមកាត់បន្ថយគម្លាតឌីជីថលក្នុងចំណោមតួអង្គពាក់ព័ន្ធ ដែលបណ្តាលមកពីគម្លាតជំនាញឌីជីថល។



## ▶ ជួយកាត់បន្ថយកម្រិតឧក្រិដ្ឋកម្ម និងការគំរាមកំហែងតាមប្រព័ន្ធ ICT

បច្ចេកវិទ្យាឌីជីថលពិតជាបានជួយសម្រួលការរស់នៅប្រចាំថ្ងៃរបស់យើង ប៉ុន្តែក៏នាំមកនូវហានិភ័យមួយចំនួន ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ទាំងផ្នែកហិរញ្ញវត្ថុ និងផ្ទាល់ខ្លួន ព្រមទាំងបណ្តាលឱ្យបាត់បង់ភាពជឿជាក់ពីសំណាក់អ្នកប្រើប្រាស់។ ក្នុងន័យនេះ តម្រូវការជំនាញឌីជីថល ជាពិសេសចំណេះដឹងទាក់ទងនឹងសន្តិសុខសាយប័រពិតជាសំខាន់។ ដូច្នេះ នៅពេលពលរដ្ឋកាន់តែច្រើនមានចំណេះដឹងទាក់ទងនឹងសុវត្ថិភាពសាយប័រ នឹងជួយកាត់បន្ថយកម្រិតហានិភ័យដែលបង្កឡើងដោយជនខិលខូចនៅលើអ៊ីនធឺណិត និងជួយពួកគេចៀសវាងក្លាយជាជនរងគ្រោះដោយសារការគំរាមកំហែងតាមប្រព័ន្ធ ICT។




## ▶ ជំរុញល្បឿននៃការត្រៀមខ្លួនឌីជីថល និងជំរុញដំណើរការបរិវត្តកម្មឌីជីថល

ការត្រៀមខ្លួនឌីជីថលសម្រាប់ពលរដ្ឋ ផ្តោតសំខាន់លើធាតុផ្សំសំខាន់ៗ រួមមាន ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, អក្ខរកម្មឌីជីថល និងការចូលរួមឌីជីថលជាដើម។ ធាតុផ្សំសំខាន់ៗទាំងនេះអាចសម្រេចកំណើននៃការចូលរួមរបស់ពលរដ្ឋបាន លុះត្រាតែពលរដ្ឋមានចំណេះដឹងទាក់ទងនឹងឌីជីថល។ ករណីនេះបង្ហាញថា ចំនួនពលរដ្ឋឌីជីថលកាន់តែច្រើននៅក្នុងប្រទេស អាចជំរុញល្បឿននៃការត្រៀមខ្លួនឌីជីថលរបស់ប្រទេសនោះជារួម។ លើសពីនេះ ពលរដ្ឋឌីជីថលក៏ជួយជំរុញដំណើរការបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសផងដែរ ព្រោះថាប្រសិនបើពលរដ្ឋមិនមានចំណេះដឹងឌីជីថលផង

ដំណើរការបរិវត្តកម្មឌីជីថលក៏មិនអាចសម្រេចបានជោគជ័យទាំងស្រុងនោះទេ។ ជាក់ស្តែង អាជីវកម្ម ឬស្ថាប័នមិនអាចជំរុញបរិវត្តកម្មឌីជីថលបានទេ ប្រសិនបើបុគ្គលិកក្នុងស្ថាប័នមិនមានសមត្ថភាព ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។



## ជំរុញការកសាងសង្គមឌីជីថល

ការកសាងសង្គមឌីជីថល ត្រូវការការចូលរួមពីកោសិកាសង្គមទាំងអស់ ពោលគឺបុគ្គលគ្រប់រូប អាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គល ក្រុមគ្រួសារ និងសហគមន៍, ការបំពេញកិច្ចការងារ និងការធ្វើអាជីវកម្មជាដើម។ នៅពេលពលរដ្ឋមានជំនាញឌីជីថលសមស្រប ពួកគេនឹងអាចទទួលបានសេវាសង្គមកាន់តែងាយស្រួល និងទូលំទូលាយ តាមរយៈថ្នាលបច្ចេកវិទ្យាឌីជីថល, អាចពង្រឹងទំនាក់ទំនង និងចែករំលែកក្នុងសង្គមបានកាន់តែត្រឹមត្រូវ និងការទទួលបានការកម្សាន្ត និងព័ត៌មានពីសង្គមតាមតម្រូវការជាដើម។



### ▶ ជំរុញការកសាងសេដ្ឋកិច្ចឌីជីថល

ការកសាងសេដ្ឋកិច្ចឌីជីថលដែលរឹងមាំ មិនមែនពឹងផ្អែកតែលើបច្ចេកវិទ្យាទំនើប ឬហេដ្ឋារចនាសម្ព័ន្ធនោះទេ ប៉ុន្តែអាស្រ័យយ៉ាងខ្លាំងលើពលរដ្ឋឌីជីថល ដែលជាកម្លាំងចលករដ៏សំខាន់។ ពលរដ្ឋឌីជីថលគឺជាឆ្អឹងខ្នងដ៏សំខាន់ក្នុងការជំរុញសេដ្ឋកិច្ចឌីជីថល ដោយសារពួកគេគឺជាកម្លាំងពលកម្មដែលមានបំណិនបច្ចេកវិទ្យាខ្ពស់ អាចបង្កើតនវានុវត្តន៍ និងបង្កើនផលិតភាពការងារបានយ៉ាងរហ័ស។ លើសពីនេះ តាមរយៈការយល់ដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុអនឡាញ និងការទិញ-លក់តាមប្រព័ន្ធអេឡិចត្រូនិក ប្រកបដោយទំនុកចិត្ត និងសុវត្ថិភាព ពួកគេបានជួយជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច (ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក), ជំរុញនវានុវត្តន៍នៅក្នុងសេដ្ឋកិច្ច និងបង្កើនតម្លាភាពក្នុងចរន្តសេដ្ឋកិច្ចជាតិទាំងមូល ដែលធ្វើឱ្យការអភិវឌ្ឍសង្គម សេដ្ឋកិច្ចទំនើបមាននិរន្តរភាព និងភាពប្រកួតប្រជែងខ្ពស់។




## III. ការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាក្នុងការកសាងពលរដ្ឋឌីជីថល

យោងតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ក្នុងឆ្នាំ២០២១ ប្រជាជនកម្ពុជាប្រមាណត្រឹមតែ **៣០%** ប៉ុណ្ណោះ មានជំនាញឌីជីថលមូលដ្ឋាន ដែលជាសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្រាវជ្រាវតាមអ៊ីនធឺណិត ការចែករំលែកព័ត៌មាន និងការទំនាក់ទំនង។ ខណៈពេលដែលនិស្សិតកម្ពុជាត្រឹមតែ **២៨%** ប៉ុណ្ណោះប្រើប្រាស់កុំព្យូទ័រសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា។ ដោយឡែក តាមការប៉ាន់ស្មានក្នុងឆ្នាំ២០២១ កម្ពុជាមានមូលធនមនុស្សដែលមានទេពកោសល្យឌីជីថលចំនួនប្រមាណ ៥ម៉ឺននាក់ ប៉ុន្តែកម្លាំងពលកម្មនៅក្នុងវិស័យ ICT ភាគច្រើនមានជំនាញកម្រិតមធ្យម និងមិនទាន់មានលក្ខណៈប្រមូលផ្តុំនៅឡើយ។ ការណ៍នេះបង្ហាញថា បើប្រៀបធៀបទៅនឹងប្រទេសផ្សេងទៀតក្នុងតំបន់ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ពលរដ្ឋកម្ពុជានៅមានភាពយឺតយ៉ាវនៅឡើយ។

## ▶ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ

ដើម្បីជាប្រយោជន៍ដល់ការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គមឌីជីថល និងបង្កើនការត្រៀមខ្លួនរបស់កម្ពុជា សំដៅបង្កើនការប្រកួតប្រជែងក្នុងតំបន់ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ បាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍចំណេះដឹង និងជំនាញឌីជីថលដល់សាធារណជន សម្រាប់ទាំងវិស័យសាធារណៈ និងឯកជន ជាពិសេសការជ្រៀតចូលដល់កម្រិតសហគមន៍មូលដ្ឋានផងដែរ តាមរយៈ៖

### ◉ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រំសមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត, ជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដោយបានកំណត់យកអាទិភាពគន្លឹះចំនួន ៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលជាអាទិភាពគន្លឹះបន្ថែមថ្មី។ រាជរដ្ឋាភិបាលបានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពលភាព និងកាលានុវត្តភាពក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និងសង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល។ ក្នុងនោះមួយក្នុងចំណោមកិច្ចការអាទិភាពនៃបញ្ចកោណទី ៥ គឺផ្តោតសំខាន់លើការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋផ្ទាល់ក៏ទទួលបានការបណ្តុះបណ្តាលជំនាញឌីជីថល ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថល។

### ◉ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥

រាជរដ្ឋាភិបាលបានដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១ - ២០៣៥** ជាមួយចក្ខុវិស័យច្បាស់លាស់មួយគឺ "ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី"។ ដើម្បីកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាតាមចក្ខុវិស័យនេះ ក្របខណ្ឌគោលនយោបាយនេះបានកំណត់យកគោលដៅចម្បងចំនួន ៥ រួមមាន៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល, ការកសាងពលរដ្ឋឌីជីថល, ការកសាងរដ្ឋាភិបាលឌីជីថលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល។ ក្នុងនោះរាជរដ្ឋាភិបាលបានកំណត់យកវិធានការគោលនយោបាយមួយចំនួន ដើម្បីផ្តោតលើការអភិវឌ្ឍជំនាញឌីជីថល ទាំងវិស័យសាធារណៈ និងវិស័យឯកជននៅគ្រប់កម្រិត និងគ្រប់ស្រទាប់ ព្រមទាំងការប្រមូលផ្តុំនូវទេពកោសល្យឌីជីថល និងការជំរុញពលរដ្ឋឌីជីថល ដែលក្នុងនោះរួមមាន វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល, វិធានការគោលនយោបាយផ្នែកបណ្តុំមូលធនមនុស្សដែលមានទេពកោសល្យឌីជីថល និងវិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល។

### ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គឺជាផែនទីបង្ហាញផ្លូវដល់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ និងជាឧបករណ៍សម្រាប់អនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** និងវិធានការគន្លឹះទាំង ៥ ដើម្បីបន្សុីគ្នារវាងកម្មវិធីនយោបាយ និងគោលនយោបាយអាទិភាពសំខាន់ៗរបស់យុទ្ធសាស្ត្រនេះ ជាមួយនឹងផែនការសកម្មភាព កម្មវិធី និងគម្រោងអាទិភាពរបស់ក្រសួង ស្ថាប័ន ដែលត្រូវទទួលបន្ទុកអនុវត្ត សំដៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍជាតិ ដែលបានរំលេចនៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**។ ក្នុងនោះ ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ក្រសួង-ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង-ស្ថាប័នចម្បងៗចំនួន ៧ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព រួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងមុខងារសាធារណៈ, ក្រសួងពាណិជ្ជកម្ម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងគណៈកម្មការរដ្ឋាភិបាលឌីជីថល។

### ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

**ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន** មានគោលបំណងជំរុញពលរដ្ឋកម្ពុជាគ្រប់រូបឱ្យក្លាយជា **"ពលរដ្ឋឌីជីថល"** ដើម្បីជាសសរស្តម្ភដ៏សំខាន់ក្នុងការគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលលើគ្រប់វិស័យ ដោយទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យា ដែលស្របតាមបញ្ចកោណទី៥ នៃបញ្ចកោណដំណាក់កាលទី ១ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។ ក្របខណ្ឌនេះគឺជាស្តង់ដាមូលដ្ឋានរួមមួយ ដែលអាចយកទៅប្រើប្រាស់ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋ ឆ្លើយតបនឹងកាលានុវត្តភាព និងបញ្ហាប្រឈមជាច្រើន ដែលកំពុងកើតមានឡើងដោយការវិវត្តឥតឈប់ឈររបស់បច្ចេកវិទ្យា។

### គំនិតផ្តួចផ្តើមអំពីចំណេះដឹងឌីជីថល

នៅដើមឆ្នាំ២០២៤ ប្រទេសកម្ពុជាបានដាក់ចេញនូវគម្រោងថ្មីមួយ គឺគំនិតផ្តួចផ្តើមអំពីអក្ខរកម្មឌីជីថល ដែលទទួលបានមូលនិធិពីមូលនិធិ Dariu និងអនុវត្តដោយ Swisscontact។ គម្រោងនេះផ្តោតលើការរួមបញ្ចូលអក្ខរកម្មឌីជីថលទៅក្នុងកម្មវិធីសិក្សារបស់សិស្សវិទ្យាល័យ និងសិស្សានុសិស្សអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលមានគោលបំណងកាត់បន្ថយគម្លាតឌីជីថល ដោយធានាថាសិស្សានុសិស្សត្រូវបានត្រៀមខ្លួនសម្រាប់តម្រូវការនៃសម័យទំនើបដែលជំរុញដោយបច្ចេកវិទ្យា។ គិតត្រឹមខែកក្កដា ឆ្នាំ២០២៥ សិស្សជាង **២២៩១នាក់** ទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ ដោយពួកគេទទួលបានចំណេះដឹងទាក់ទងនឹងការសរសេរកូដ ការគិតបែប Algorithmic និងការធ្វើអន្តរកម្មរវាង Hardware – Software។

## ◉ សម្ព័ន្ធភាព Game Changers

អង្គការ UNICEF បានរៀបចំគំនិតផ្តួចផ្តើម **សម្ព័ន្ធភាព Game Changers** នេះឡើង គឺសម្រាប់ក្មេងស្រី និងយុវជន ដើម្បីឱ្យពួកគេនូវបទពិសោធជាក់ស្តែងក្នុងការសរសេរកូដ ការរចនា និងគោលគំនិតអក្ខរកម្មហិរញ្ញវត្ថុជាដើម។ នៅក្នុងគំនិតផ្តួចផ្តើមនេះផងដែរ អង្គការ UNICEF បានសហការជាមួយក្រុមហ៊ុន Bitget ដោយក្រុមហ៊ុនបានគាំទ្រកម្មវិធីជំនាញឌីជីថលសម្រាប់ក្មេងស្រីវ័យជំទង់ដែលប្រើប្រាស់ការអភិវឌ្ឍហ្គេមវីដេអូ ដើម្បីជាមូលដ្ឋានទៅការសរសេរកូដ និងការរៀនសូត្រទាក់ទងនឹងបច្ចេកវិទ្យាផ្សេងទៀត។ សម្ព័ន្ធភាពនេះក៏មានវត្តមាននៅកម្ពុជា ដោយផ្តល់ជាកន្លែងដែលសិស្សអាចចូលរួមក្នុងការបង្កើតហ្គេម និងកម្មវិធី Pitching ជាដើម។ គំនិតផ្តួចផ្តើមនេះបានផ្តល់ឱកាសដល់ក្មេងស្រីក្នុងការចូលរួមធ្វើបរិវត្តកម្មឌីជីថលនៅក្នុងប្រទេស តាមរយៈការជួយឱ្យពួកគេអាចក្លាយជាអ្នកបង្កើត អ្នកច្នៃប្រឌិត និងជាអ្នកដឹកនាំក្នុងយុគសម័យឌីជីថល ដោយលុបបំបាត់គម្លាតយេនឌ័រក្នុងការអប់រំឌីជីថល និងធានាការទទួលបានឱកាសសិក្សាទំនើបប្រកបដោយសមធម៌។ តាមរយៈការសរសេរកូដ ការដោះស្រាយបញ្ហា និងការធ្វើការងារជាក្រុម ក្មេងស្រីអាចកសាងភាពជាអ្នកដឹកនាំ និងជំនាញអក្ខរកម្មឌីជីថល ដែលអាចឱ្យពួកគេចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍជាតិ។

## ▶ ឧបសគ្គសំខាន់ៗ ដែលរារាំងការទទួលយកឌីជីថល (Digital Adoption)

បើទោះបីជាកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅរកការកសាងសេដ្ឋកិច្ច សង្គមឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក៏ដោយ បញ្ហាប្រឈមមួយចំនួននៅតែបន្តរារាំងល្បឿននៃការអនុវត្តការងារនេះ។ បើទោះបីជាការប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញសង្គមមានការកើនឡើងខ្លាំងក៏ដោយ ក៏ការទទួលយកឌីជីថលពេញលេញសម្រាប់បម្រើដល់ការបំពេញកិច្ចការងារ អាជីវកម្ម និងការអប់រំ នៅតែមានឧបសគ្គមួយចំនួន ដូចជា៖

### ◉ កម្រិតចំណេះដឹងឌីជីថលនៅមានកម្រិត

ប្រជាជនកម្ពុជាភាគច្រើនប្រើប្រាស់ឧបករណ៍ឌីជីថល ជាពិសេសទូរសព្ទដៃ សម្រាប់តែការកម្សាន្ត និងការប្រើប្រាស់បណ្តាញសង្គម (Facebook, TikTok, Telegram) តែប៉ុណ្ណោះ ក្នុងនោះចំនួនប្រជាជនដែលមានសមត្ថភាពប្រើប្រាស់ឧបករណ៍ទាំងនោះសម្រាប់កិច្ចការដែលផ្តល់ផលិតភាពខ្ពស់នៅតែមានកម្រិតទាបនៅឡើយ ដោយសារខ្វះចំណេះដឹងផ្នែកឌីជីថល។

### ◉ ផ្នែកហិរញ្ញវត្ថុក្នុងការទិញឧបករណ៍ទំនើបៗ និងសេវាអ៊ីនធឺណិត

បើទោះបីជាតម្លៃអ៊ីនធឺណិតនៅកម្ពុជាមានលក្ខណៈសមរម្យធៀបនឹងប្រទេសជិតខាង ប៉ុន្តែតម្លៃនៃឧបករណ៍ឆ្លាតវៃ (Smartphones/Laptops) ដែលមានគុណភាពអាចគាំទ្រកម្មវិធីទំនើបៗបាននៅតែមានតម្លៃខ្ពស់សម្រាប់ប្រជាជនដែលមានចំណូលទាប និងមធ្យម។ បន្ថែមពីនេះ ការចំណាយលើទិន្នន័យអ៊ីនធឺណិត (Data) សម្រាប់ការប្រើប្រាស់ជាប់លាប់ក៏ជាបន្ទុកមួយសម្រាប់សិស្សនិងប្រជាជននៅតំបន់ជនបទ។

### ហេដ្ឋារចនាសម្ព័ន្ធ និងសេវាគ្របដណ្តប់

នៅតាមបណ្តាខេត្ត និងតំបន់ដាច់ស្រយាល ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងវិសាលភាពនៃសេវាគ្របដណ្តប់នៅមានកម្រិតនៅឡើយ ដោយសេវាអ៊ីនធឺណិតជួបប្រទះបញ្ហារអាក់រអួល និងមានល្បឿនយឺត។ ការខ្វះខាតខ្សែបញ្ជូនអុបទិក (Fiber Optic) នៅតាមសហគមន៍ជនបទ ធ្វើឱ្យការទាញយកប្រយោជន៍ពេញលេញពីការប្រើប្រាស់ឧបករណ៍ឌីជីថលនៅមិនទាន់អស់សក្តានុពល។

### ក្តីបារម្ភលើបញ្ហាសុវត្ថិភាពអ៊ីនធឺណិត

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បញ្ហានៃការលួចគណនី (Hacking) និងការបោកប្រាស់តាមកម្មវិធីតេឡេក្រាម ឬការវិនិយោគអនឡាញមានការកើនឡើង។ កត្តានេះធ្វើឱ្យប្រជាជនមួយចំនួនធំមានការភ័យខ្លាច និងមិនហ៊ានប្រើប្រាស់សេវាឌីជីថល ជាពិសេសសេវាធនាគារ ឬការទិញទំនិញតាមអនឡាញ។

### របាំងភាសា

ឧបករណ៍ និងកម្មវិធីឌីជីថលភាគច្រើនប្រើប្រាស់ភាសាអង់គ្លេសជាគោល។ បើទោះបីជាមានការបកប្រែជាភាសាខ្មែរខ្លះក៏ដោយ ក៏វាក្យសព្ទបច្ចេកទេសនៅតែជាឧបសគ្គសម្រាប់អ្នកដែលមិនចេះភាសាបរទេស ដែលធ្វើឱ្យពួកគេពិបាកក្នុងការស្វែងរក និងយល់ពីការប្រើប្រាស់មុខងាររបស់ឧបករណ៍ឌីជីថលនានាផងដែរ។ ជាក់ស្តែង សហគមន៍ជនជាតិដើមភាគតិចជាច្រើននៅតាមបណ្តាខេត្តនៅតែមានគម្លាតឆ្ងាយពីប្រព័ន្ធឌីជីថល ដោយពួកគាត់ខ្វះលទ្ធភាពទទួលបានព័ត៌មាន ដោយសារតែឧបសគ្គភាសា និងតំបន់ខ្លះនៅតែមិនទាន់មានសេវាអ៊ីនធឺណិតគ្រប់គ្រាន់។

## IV. សេចក្តីសន្និដ្ឋាន

ជារួម បច្ចេកវិទ្យា បានផ្លាស់ប្តូររបៀបរបបនៃការរស់នៅ ការសិក្សា និងការធ្វើអាជីវកម្មឱ្យកាន់តែមានភាពរស់រវើក និងឆ្លើយតបបានទាន់ពេលវេលាចំពោះតម្រូវការជាក់ស្តែង។ ការណ៍នេះ បានធ្វើឱ្យអក្ខរកម្មឌីជីថល និងពលរដ្ឋឌីជីថល ក្លាយជាកាតាលីករដ៏សំខាន់ នៃយុគសម័យឌីជីថល ដែលជួយជំរុញទាំងប្រសិទ្ធភាពការងារ តម្លាភាព ការទទួលខុសត្រូវខ្ពស់ក្នុងសង្គម និងជាពិសេសការកសាងសេដ្ឋកិច្ច សង្គមឌីជីថល។ ដោយមើលឃើញពីអត្ថប្រយោជន៍របស់ពលរដ្ឋឌីជីថល ប្រទេសកម្ពុជាក៏មិនខុសគ្នាពីប្រទេសដទៃទៀត បើទោះបីជានៅក្នុងដំណើរការអនុវត្តបានជួបប្រទះឧបសគ្គមួយចំនួនក៏ដោយ ក៏រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនៅតែបន្តយកចិត្តទុកដាក់លើការជំរុញការកសាងពលរដ្ឋឌីជីថល តាមរយៈការបន្តអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមជាច្រើនដែលបានដាក់ចេញ និងព្យាយាមស្វែងរកដំណោះស្រាយបន្ថែមដើម្បីជំរុញការបណ្តុះបណ្តាលជំនាញឌីជីថលដល់សាធារណជន សំដៅកាត់បន្ថយគម្លាតឌីជីថល និងជំរុញឱ្យពលរដ្ឋគ្រប់រូបក្លាយជាពលរដ្ឋឌីជីថល៕

## ឯកសារយោង


- *Digital Citizen*, ចូលអានថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://shorturl.at/QvYKG
- *Effect of Digital Citizenship on Prevention of Cybercrime*, ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://encyclopedia.pub/entry/48495
- *Impact of Digital Capabilities on Digital Transformation*, ចេញផ្សាយថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://shorturl.at/bgdzq
- *FRAMEWORK FOR DEVELOPING DIGITAL READINESS AMONG ASEAN CITIZENS*, ចេញផ្សាយខែមីនា ឆ្នាំ២០២១, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦
- *How Cambodia's Students Are Thriving Through Digital Literacy*, ចេញផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥, ចូលអានថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://shorturl.at/6Gh9x
- *Bitget backs UNICEF games scheme for Cambodian girls*, ចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ២០២៥, ចូលអានថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://tinyurl.com/3m5642ax
- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ចេញផ្សាយខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, ចេញផ្សាយខែឧសភា ឆ្នាំ២០២១, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, ចេញផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦
- ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន, ចេញផ្សាយខែមិថុនា ឆ្នាំ២០២៤, ចូលអានថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦
- *Digital literacy, ethical AI key to Cambodia's future*, ចេញផ្សាយថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://tinyurl.com/59vwnywc
- *Embarking on the Digital Journey: Addressing Cambodia's Digital Government Challenges*, ចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦, https://tinyurl.com/2n34nstr
- តើអ្វីទៅជា អក្ខរកម្មឌីជីថល និងគម្លាតឌីជីថល?, ចេញផ្សាយថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦, https://www.interior.gov.kh/news/2ZUGFRKid05L
- *Digital Technology in Cambodia: Challenges and Opportunities*, ចេញផ្សាយថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦, https://tinyurl.com/32raa67a
- *"We Have Eyes to Watch but Cannot Understand": The Language Gap in Cambodia's Digital Divide*, ចេញផ្សាយថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦, https://tinyurl.com/ypd7ewcx


---

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center